# ជំពូក ៦

# ការប្រឹក្សា និង ពិគ្រោះយោបល់ ពីសាធារណជន

## Public Consultation

Draft

# ជំពូកទី ៦

# ការប្រឹក្សា និង ពិគ្រោះយោបល់ ពីសាធារណៈជននៅក្បែរតំបន់គំរោង

## ៦.១ សេចក្តីផ្តើម

ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជនដែលពាក់ព័ន្ធដោយសារគំរោងនេះ គឺជាចំណុចមួយដ៏សំខាន់ដែលធ្វើឡើងដើម្បីឱ្យសាធារណៈជនដែលពាក់ព័ន្ធទាំងនេះផ្តល់នូវមតិយោបល់ និងសំណូមពរក្នុងការជួយដល់ការអនុវត្តន៍គំរោងឱ្យបានល្អប្រសើរ និងមានភាពរលូន ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ ធ្វើឡើងនូវដំណាក់កាលរចនាគំរោង ដែលធ្វើឱ្យសាធារណៈជនពាក់ព័ន្ធទាំងនោះបានដឹងឮថា មានក្រុមហ៊ុន នឹងមកវិនិយោគលើការសាងសង់វារីអគ្គសនីក្នុងតំបន់របស់គាត់ ។

រយៈពេលការធ្វើការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជន ដែលពាក់ព័ន្ធដោយសារគំរោងនេះ គឺអស់រយៈពេលជាង ១ ខែ (០៦/១១/២០០៧ ដល់ ១៤/១២/២០០៧) ។

ការប្រឹក្សា និងពិគ្រោះយោបល់នេះ បានធ្វើការពិភាក្សាវែកញែក និងពន្យល់ដល់ស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងបានយល់ អំពីគោលបំណងនៃការអភិវឌ្ឍន៍គំរោង ដែលទៅថ្ងៃអនាគតនឹងនាំឱ្យពួកគាត់បានរីកចំរើន (ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង) ។

## ៦.២ គោលបំណងនៃការប្រឹក្សា

ការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជន មានគោលបំណងដូចតទៅ :

- ធ្វើការផ្សព្វផ្សាយដល់សាធារណៈជន និងអ្នកដែលពាក់ព័ន្ធនឹងគំរោងទាំងអស់បានដឹងឮអំពីគោលបំណង និងដំណាក់កាលនៃការអនុវត្តន៍គំរោងនេះ ។
- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអរផ្សេងៗរបស់ពួកគេទាំងនោះ ។
- ធ្វើការដោះស្រាយទំនាស់ទាំងនោះដោយធ្វើការប្រជុំពិភាក្សាជាមួយគាត់និងមានការចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធក្នុងតំបន់គំរោង ។

## ៦.៣ កំណត់ហេតុនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជន

ក្រុមការងារសិក្សាស្រាវជ្រាវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងរបស់ SAWAC បានធ្វើការប្រឹក្សា និងពិគ្រោះយោបល់ពីសំណាក់សាធារណៈជនដែលពាក់ព័ន្ធមានដូចតទៅ :

- នាយកខុទ្ទកាល័យ សាលាខេត្ត កោះកុង
- មន្ទីរបរិស្ថាន ខេត្ត កោះកុង
- មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកោះកុង
- មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកោះកុង
- មន្ទីរកសិកម្ម ខេត្តកោះកុង
- ខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកោះកុង



Draft

- មន្ទីររៀបចំដែនដី នគររូបនីយកម្ម និង សំណង់ ខេត្តកោះកុង
- សាលាស្រុកថ្មបាំង ( អភិបាលរងស្រុកថ្មបាំង )
- សាលាឃុំថ្មដូនពៅ ( មេឃុំ និងគណៈកម្មការអភិវឌ្ឍន៍ឃុំ)
- សាលាឃុំ ជំនាប់ ( មេឃុំ និងគណៈកម្មការអភិវឌ្ឍន៍ឃុំ)
- មេឃុំ ប្រឡាយ ( មេឃុំ និងគណៈកម្មការអភិវឌ្ឍន៍ឃុំ)
- និងប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ ឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំប្រឡាយ ។

**៦.៣.១ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយ អ្នកគ្រប់គ្រងគំរោងរបស់ក្រុមហ៊ុន CSG**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **លីញ ជៀនហ្វេង** ( Ling Jianfeng ) អ្នកគ្រប់គ្រងគំរោងរបស់ក្រុមហ៊ុន CSG ធ្វើឡើងនៅម៉ោង ១០:០០ ដល់ ១១ : ៣០ ថ្ងៃទី ០៦/១១/២០០៧ មានដូចតទៅ :

លោកបានមានប្រសាសន៍ថា :

- កន្លែងសាងសង់ ទំនប់ត្រូវបានជ្រើសរើសពីរកន្លែងគឺ : Site A, Site B ។ ទំនប់នៅ Site A បានខួងជំរៅ ៦០ម នៅចំនុច Powerhouse ជំរៅ១០០ម Site B មិនទាន់បានធ្វើការសិក្សាទេ មូលហេតុ រដូវភ្លៀង ជំងឺគ្រុញចាញ់ ។ លទ្ធផលខួងនៅ Site A បានឱ្យដឹងថា គុណភាពគ្រឹះថ្មមានលក្ខណៈខ្សោយ ដោយមានលាយស្រទាប់ដីក្នុងថ្ម ដែលជាហេតុអាចបណ្តាលឱ្យមានការស្រុត នៅពេលលើកទំនប់ទប់ ។ ក៏ប៉ុន្តែកន្លែងនេះអាចសាងសង់ទំនប់បានដោយធ្វើការងារគ្រឹះដោយចំណាយច្រើនបន្តិច ។ ចំពោះនៅចំនុច powerhouse គុណភាពគ្រឹះថ្មបាតក្រោម គឺល្អជាងកន្លែងទំនប់ Site A ។
- រីឯនៅផ្នែកខាងលើទំនប់ Site A គំរោងបានចុះទៅដល់ចំនុចសិក្សាដែលបានគ្រោងទុករួចរាល់ហើយ តែការធ្វើដំណើរតាមម៉ូតូ ពីអារ៉ែងទៅដល់ភូមិចំណារត្រូវប្រើរយៈពេល៣ម៉ោង ហើយមានកន្លែងខ្លះត្រូវសែងម៉ូតូកាត់អូរ ចំពោះខែវស្សា ពិបាកចូលម៉ូតូណាស់ ។
- បើតាមបទពិសោធន៍របស់គាត់ក្នុងការសាងសង់ទំនប់វារីអគ្គិសនីនេះបានឱ្យដឹងថា ទោះបីបាតទំនប់មានដង់ស៊ីតេថ្មទាបក៏ដោយ ក៏អាចធ្វើបានដែរ តែត្រូវមានលក្ខណៈបច្ចេកទេសខ្ពស់ និងច្បាស់លាស់ ហើយបានអះអាងបន្ថែមថា ក្រុមហ៊ុនរបស់គាត់ធ្លាប់បានចូលរួមសិក្សាទំនប់វារីអគ្គិសនីធំៗមួយចំនួននៅប្រទេសចិន ដូចជា ទំនប់វារីអគ្គិសនីនៅទន្លេយ៉ង់សេជាដើម ។

**៦.៣.២ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ប៉ិច ស៊ីយ៉ុន** ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកោះកុង ធ្វើឡើងនៅម៉ោង ១៥:០០ ដល់ ១៦ : ៣០ ថ្ងៃទី ០៦/១១/២០០៧ មានដូចតទៅ :

- លោកគាំទ្រគំរោងសាងសង់វារីអគ្គិសនីរបស់រាជរដ្ឋាភិបាល
- គួរសិក្សារកតុល្យភាពចំណេញ ឬខាតផងដែរ ( បើសិនមានការចំណេញសំរាប់ប្រទេស គឺយើងត្រូវតែធ្វើ)
- មានការព្រួយបារម្ភអំពីការបាត់បង់រ៉ែខ្សាច់គួរសិក្សាឱ្យបានស៊ីជំរៅផង

Draft

- លោកបានបញ្ជាក់ទៀតថា សព្វថ្ងៃនៅប្រទេសយើងមានវ៉ារីអគ្គិសនីតែ ២ កន្លែងប៉ុណ្ណោះ ហើយដោយឡែកនៅកោះកុងនេះយើងប្រើភ្លើងមកពីប្រទេសថៃ ដែលមានតំលៃថោកជាងម៉ាស៊ីនភ្លើង ដែលផលិតអគ្គិសនីនៅក្នុងខេត្តកោះកុងនេះ ហេតុដូចនេះហើយ គំរោងវ៉ារីអគ្គិសនីជាយអារ៉ែងនេះគួរតែសាងសង់ ដែលអាចសង្ឃឹមថា មានតំលៃភ្លើងថោក ហើយម្ចាស់ការក្នុងការផ្គត់ផ្គង់ថាមពលទៀតផង ។
- លោកក៏បានសំណូមពរឱ្យក្រុមការងារ SAWAC ធ្វើការសិក្សាលើផលប៉ះពាល់បរិស្ថានឱ្យបានស៊ីជំរៅ និងធ្វើការគណនាថវិកាសម្រាប់ការគ្រប់គ្រងបរិស្ថានឱ្យបានសមស្របតាមបច្ចេកទេស ។
- លោកក៏បានផ្តល់ឯកសារទាក់ទងនឹងគំរោងមួយចំនួនដល់ក្រុមការងារផងដែរ ។

**៦.៣.៣ កំណត់ហេតុនៃការប្រជុំពិភាក្សារបស់ក្រុមការងារជាមួយ នាយខុទ្ទកាល័យ សាលាខេត្តកោះកុង**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **អ៊ុន ឆាលី** នាយខុទ្ទកាល័យ សាលាខេត្តកោះកុង ធ្វើឡើងនៅម៉ោង ០៨:៣០ ដល់ ០៩ : ៣០ ថ្ងៃទី ០៧/១១/២០០៧ មានដូចតទៅ :

- លោកស្វាគមន៍ចំពោះគំរោងនេះ ដោយសារយើងមានភ្លើងខ្លួនឯង អាចមានតំលៃថោក ។
- លោកបានមានប្រសាសន៍ថា SAWAC ត្រូវតែសិក្សាឱ្យបានច្បាស់លាស់ពីទំហំនៃការលិចលង់ និងប៉ះពាល់ដល់ភូមិដ្ឋាន ដីស្រែចំការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់គំរោង ។
- ក្រោយពីសិក្សាចប់របាយកាណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវផ្ញើជូនសាលាខេត្តដើម្បីឱ្យសាលាខេត្តជ្រាប និងមានវិធានការ ។
- ត្រូវធ្វើការទំនាក់ទំនង និងប្រឹក្សាយោបល់ជាមួយមន្ទីរពាក់ពន្ធ័ និងអាជ្ញាធរមូលដ្ឋាន ហើយនឹងអង្គការមួយចំនួន ដើម្បីដកស្រង់ពតិមានឱ្យបានលំអិត ។
- ចំពោះផែនការជន្លៀសប្រជាពលរដ្ឋដែលលិចលង់ដោយសារការសាងសង់នេះ សាលាខេត្តនឹងបង្កើតគណៈកម្មការចុះសិក្សាជាក់ស្តែងដើម្បីកំណត់ទីតាំងលំនៅដ្ឋានថ្មី ។

**៦.៣.៤ កំណត់ហេតុនៃការប្រជុំពិភាក្សារបស់ក្រុមការងារជាមួយតំណាងមន្ទីរបរិស្ថាន ខេត្តកោះកុង**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ខៃ ពេជរតនា** ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង ធ្វើឡើងនៅម៉ោង ១០:០០ ដល់ ១១ : ០០ ថ្ងៃទី ០៧/១១/២០០៧ មានដូចតទៅ :

- លោកបានគាំទ្រទាំងស្រុងលើការអភិវឌ្ឍន៍គំរោងសាងសង់វ៉ារីអគ្គិសនីនៅឆែងអារ៉ែងនេះ ពីព្រោះលោកសង្ឃឹមថា តំលៃអគ្គិសនីនឹងមានថោក ហើយយើងមានថាមពលអគ្គិសនីគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍ប្រទេសក៏ដូចជាខេត្តកោះកុងផងដែរ ។
- លោកក៏បានបញ្ជាក់ថា ត្រូវសិក្សាហេតុប៉ះពាល់បរិស្ថានធម្មជាតិ គឺធ្វើយ៉ាងណាឱ្យមានការកាត់បន្ថយផលប៉ះពាល់ទៅលើ ព្រៃឈើ សត្វព្រៃ និង មច្ឆជាតិដែលមាននៅក្នុងតំបន់គំរោង ។
- SAWAC ត្រូវសហការជាមួយអង្គការ WildAid និង CI ដែលជាអង្គការអភិរក្ស និងការពារធនធានធម្មជាតិនៅតំបន់នោះ ។

Draft

- ចំពោះទីសក្ការៈបូជារបស់ជនជាតិភាគតិចនៅតំបន់នោះត្រូវមានការសួរយោបល់ពីប្រជាពលរដ្ឋ និងរកដំណោះស្រាយសមស្រប ។
- លោកមិនទាន់បានដឹងនូវការចុះអនុស្សរណៈរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិននៅឡើយគ្រាន់តែដឹងថា មានការចុះអនុស្សរណៈរវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន CSG របស់ចិន តាមរយៈការបង្ហាញរបស់ SAWACតែប៉ុណ្ណោះ ។
- លោកបានបន្ថែមទៀតថា មុខសញ្ញាការពារសំខាន់នៅតំបន់នោះគឺ ក្រពើភ្នំ ដំរី ត្រីនាគ និង ពូជឈើសំខាន់ៗ ។
- លោកបានសំណូមពរថា ត្រូវតែធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានល្អិតល្អន់ ពីព្រោះការសាងសង់ទំនប់វារីអគ្គិសនីនេះ វាមានផលប៉ះពាល់ច្រើនទាំងបរិស្ថានធម្មជាតិ និង សង្គម ។

**៦.៣.៥ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងមន្ទីរធនធានទឹក ខេត្តកោះកុង**

ការប្រជុំពិភាក្សានិងប្រឹក្សាយោបល់ជាមួយ លោក **សាញ់ មុនីរត្ន** ប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកោះកុង ធ្វើឡើងនៅម៉ោង ១៤ : ០០ ដល់ ១៥ : ០០ ថ្ងៃទី ០៧/១១/២០០៧ មានដូចតទៅ :

- លោកបានមានប្រសាសន៍ថា លោកគាំទ្រនូវគំរោងវារីអគ្គិសនីជាយអារ៉ែងនេះ ប៉ុន្តែក្រុមហ៊ុនគួរតែសុំច្បាប់ទៅក្រសួងធនធានទឹក ដែលពាក់ព័ន្ធនឹងការសាងសង់ ទំនប់វារីអគ្គិសនីនេះ ពីព្រោះច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានអនុម័តរួចហើយ ដោយរដ្ឋសភាជាតិ ។
- លោកធ្លាប់បានផ្តល់ទិន្នន័យទឹកភ្លៀងឱ្យទៅក្រុមហ៊ុនចិននេះម្តងដែរ តែក្រោយមកបាត់រហូតគ្មានទំនាក់ទំនងអ្វីទៀតឡើយ ។
- តាមការចុះស្រាវជ្រាវរបស់មន្ទីរធនធានទឹកនៅរដូវប្រាំងបានឱ្យដឹងថា ត្រីនាគរស់នៅក្នុងអន្លង់ជាមួយសត្វក្រពើ ហើយនៅទីនោះសំបូរត្រីខ្មៅទៀតផង។
- លោកមានចំណាប់អារម្មណ៍ថា ជាធម្មតាការសាងសង់អ្វីក៏ដោយត្រូវតែមានការប៉ះពាល់ដែរ តែការសាងសង់វារីអគ្គិសនីនេះ មានផលប៉ះពាល់ធំធេងលើធនធានធម្មជាតិ និងសង្គម ហើយត្រូវតែថ្លឹងថ្លែងថា ការធ្វើវារីអគ្គិសនីចំណេញ ឬការទុកអភិរក្សដោយគ្មានគំរោងនៅតំបន់នោះ មួយណាចំណេញជាង ។
- លោកបានមានប្រសាសន៍ថា នៅទីនោះមានប្រជាពលរដ្ឋប្រមាណ ១.០០០នាក់ ប្រហែលជាមានបញ្ហាតិចតួចដល់ប្រជាពលរដ្ឋប៉ុណ្ណោះ ប៉ុន្តែសូមឱ្យក្រុមការងារ SAWAC សិក្សាលំអិតផង ។
- លោកមានសំណូមពរថា ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន គួរតែសិក្សាផ្តោតទៅលើធនធានធម្មជាតិ និងរកវិធានការកាត់បន្ថយនៃការប៉ះពាល់ដល់ធនធានធម្មជាតិទាំងនេះឱ្យបានកំរិតទាបបំផុតនៃការប៉ះពាល់នេះ ។
- មុននឹងអនុវត្តគំរោងត្រូវមានអាជ្ញាប័ណ្ណធនធានទឹកជាមុនសិន ជៀសវាងមានទំនាស់ក្នុងការប្រើប្រាស់ទឹកការលិចលង់ ។ល ។

Draft

- លោកបានផ្តល់អនុសាសន៍ថា ប្រជាពលរដ្ឋក្នុងតំបន់ ជាពិសេសភូមិ ឃុំដែលប៉ះពាល់ គួរតែផ្តល់ភ្លើងអគ្គិសនីដែលចេញពីវារីអគ្គិសនីនេះ ហើយមានតំលៃថោកទៀតផង ។
- លោកសំណូមពរឱ្យ SAWAC ផ្តល់របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តហើយទុកជាឯកសារ ។

### ៦.៣.៦ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងមន្ទីរកសិកម្មខេត្តកោះកុង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ផុន លីវិរៈ** ប្រធានមន្ទីរ និង លោក **ឡាង គីរី** អនុប្រធានការិយាល័យជលផលស្តីទី នៃមន្ទីរកសិកម្មខេត្តកោះកុង ធ្វើឡើងនៅ ម៉ោង ០៨:៣០ ដល់ ០៩ : ៣០ ថ្ងៃទី ០៨/១១/២០០៧ ហើយលោកតំណាងមន្ទីរបានមានប្រសាសន៍ដូចតទៅ :

- គាំទ្រលើគំរោងអភិវឌ្ឍន៍វារីអគ្គិសនីនៅខេត្តកោះកុងនេះ ពីព្រោះវាផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់ប្រជាពលរដ្ឋ និងប្រទេសជាតិទាំងមូល ។
- ចំពោះការប៉ះពាល់ដល់ដីកសិកម្ម និងលំនៅដ្ឋានដល់ប្រជាពលរដ្ឋ មន្ទីរមិនទាន់សិក្សានៅឡើយទេ SAWAC គួរសិក្សាទំហំប៉ះពាល់នោះឱ្យបានច្បាស់លាស់ផង ។
- បញ្ហាត្រីនាគដែលជាប្រភេទត្រីកំរ កំពុងមានការអភិរក្ស តែមិនទាន់មានអនុក្រិត្យការពារត្រីនេះនៅឡើយទេ ហើយយើងអាចសំរបសំរួលជាមួយនឹងអង្គការអភិរក្ស និងការពារក្នុងតំបន់នោះ ដើម្បីអភិវឌ្ឍន៍គំរោងវារីអគ្គិសនីនេះបាន ។
- បញ្ហាក្រពើដែលជាប្រភេទក្រពើកំរនោះ ជាក្រពើដោយមានការការពារដោយអង្គការ CI និងអង្គការ Fauna & Flora International ។
- សត្វទោចជាប្រភេទសត្វដែលជិតផុតពូជ បច្ចុប្បន្ននេះមានអង្គការមួយជួយការពារដែរ ។
- អង្គការនៅតំបន់គំរោងមិនត្រឹមជួយការពារសត្វព្រៃទេ តែថែមទាំងជួយដល់ការប្រកបអាជីវកម្មកសិកម្មផងដែរ ។
- ចំពោះពត៌មានអំពីព្រៃឈើ ជាប្រភេទព្រៃល្បោះ ពាក់កណ្តាលស្រោង និងព្រៃស្រោង សូមក្រុមការងារនេះធ្វើការសិក្សានៃប្រភេទព្រៃឈើទាំងនេះផង ។
- សព្វថ្ងៃ WildAid កំពុងធ្វើការទិទៀន និងតវ៉ាចំពោះគំរោងរបស់ចិន និងគំរោងរបស់ជប៉ុន នៅក្នុងខេត្តកោះកុង ពីព្រោះអង្គការទាំងនោះតែងតែអះអាងថា រដ្ឋាភិបាលបានធ្វើអនុស្សរណៈផ្តល់តំបន់ភ្នំក្រវាញនេះជាតំបន់អភិរក្សសត្វព្រៃ និងព្រៃឈើ ។ ហេតុដូចនេះហើយ សូមឱ្យក្រុមការងារ SAWAC ទៅប្រឹក្សាយោបល់ពីអង្គការទាំងនេះផង (WildAid & CI) ។
- សំណូមពរសំខាន់ គឺមន្ទីរកសិកម្មចង់រកដំណោះស្រាយយ៉ាងណាឱ្យមានការដោះដូរដីជាមួយប្រជាពលរដ្ឋដែលប៉ះពាល់ក្នុងតំបន់គំរោងឱ្យបានសមស្រប និងយុត្តិធម៌ទៅតាមច្បាប់ ។

Draft

**៦.៣.៧ តំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកោះកុង**

ការប្រជុំពិភាក្សានិងប្រឹក្សាយោបល់ជាមួយ លោក **មាស ស៊ីថា** នាយរងខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តកោះកុង និងលោក **ម៉ឹង មៅរ៉ា** នាយរងផ្នែករដ្ឋបាលព្រៃឈើដងទង់ ធ្វើឡើងនៅម៉ោង ១៤ : ០០ ដល់ ១៥ : ០០ ថ្ងៃទី ០៨/១១/២០០៧ ហើយលោកតំណាងខ័ណ្ឌរដ្ឋបាលព្រៃឈើនេះបានមានប្រសាសន៍ ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- ចំពោះផែនការមេនៃការសាងសង់វារីអគ្គិសនីនេះ លោកមិនបានដឹងទេ តែដឹងថា មានការអភិវឌ្ឍន៍វារីអគ្គិសនី នឹងមានការប៉ះពាល់ ពីព្រោះតំបន់នោះជាតំបន់អភិរក្សសត្វព្រៃ ។
- លោកគាំទ្រនូវការអភិវឌ្ឍន៍គំរោងនេះ ក៏ប៉ុន្តែគួរថ្លឹងថ្លែងនូវការបាត់បង់ដោយសារគំរោង និងការបានចំណេញពីគំរោងផងចំពោះការអភិវឌ្ឍន៍នេះ ។
- ក្រពើភ្នំដែលពេញវ័យអាចចរាចរទៅកន្លែងផ្សេងហើយនៅរដូវប្រាំង វាអាចចរាចរបានដល់ទៅ ៥០ គ.ម. ទៅខាងលើភ្នំ ហើយពួកវាអាចអត់ចំណីដល់ទៅ ២ ខែឯណោះ ។ ពពួកក្រពើនេះពងនៅខែ ៤ ដែលពួកវាវិលទៅរកកន្លែងសំបុកដើមរបស់ពួកវាវិញ ។
- ចំពោះផលប្រយោជន៍អគ្គិសនីធំជាងក្រពើ ឬ យ៉ាងណានោះខ្ញុំមិនដឹងទេ តែជាក់ស្តែងប្រហែលជាមិនបាត់ពពួកក្រពើនោះទាំងស្រុងទេ ពីព្រោះមានអាងទឹកដ៏ធំអាចធ្វើឱ្យវាផ្លាស់ទីបានទៅរស់នៅកន្លែងផ្សេងទៀត គឺគ្រាន់តែបាត់បង់សំបុកវាប៉ុណ្ណោះ ។
- អាចបំពុលទឹក ដោយសារការរលួយស្អុយនៃរុក្ខជាតិដែលដុះនៅក្នុងអាង ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុខភាពទាំងសត្វ ទាំងមនុស្ស ។
- ការទប់ទំនប់ធ្វើអាងដ៏ធំនេះ អាចមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស និងសត្វ ដោយសារការបាក់ទំនប់នេះ ដោយប្រការណាមួយ ។
- តំបន់ភ្នំក្រវាញមានសក្តានុពលធម្មជាតិល្អ ដែលប្រទេសជិតខាងគ្មានប្រដូចទេ ពោលគឺ មានជីវសាស្ត្រចំរុះគ្រប់ប្រភេទ ដែលអាចធ្វើទេសចរណ៍ ឬទុកជាកេរតំណែលធម្មជាតិសម្រាប់ប្រទេសកម្ពុជាដល់អ្នកជំនាន់ក្រោយ ។
- តំបន់គំរោង ជាកន្លែងដំរីឆ្លងកាត់ឆ្ពោះទៅឧទ្យានជាតិគីរីរម្យ គឺភាគច្រើនពួកវាដើរក្បែរជើងភ្នំ តំបន់វាលស្មៅគ្មានមនុស្សរំខាន ។ ម្យ៉ាងទៀត ពេលធ្វើទំនប់វារីអគ្គិសនីអាចលិចដីព្រៃ ដីវាលស្មៅទាំងនោះ ក៏ប៉ុន្តែពពួកដំរីទាំងនេះវាអាចចល័តទៅកន្លែងផ្សេងទៀតបាន ។
- អាចប៉ះពាល់ដល់ការចរាចរត្រី ក្រពើ និងសត្វដំរី ពីព្រោះលក្ខណៈភូមិសាស្ត្រតំបន់ជ្រលងឆែងអារ៉ែង មានលក្ខណៈល្អជាងកន្លែងផ្សេងទៀត ។

**សំណូមពរ :**

- ពេលកាប់ឈើក្រុមហ៊ុនសូមសហការជាមួយរដ្ឋបាលព្រៃឈើ ដើម្បីបង់ពន្ធតំលៃឈើជូនរដ្ឋ ។
- សូមឱ្យក្រុមហ៊ុនមានមូលនិធិគ្រប់គ្រាន់សម្រាប់ការអភិរក្ស និងគ្រប់គ្រងសត្វព្រៃជុំវិញ និងក្នុងតំបន់គំរោង

Draft

- សូមឱ្យក្រុមហ៊ុនមានមូលនិធិគ្រប់គ្រាន់សម្រាប់ការដាំឈើឡើងវិញ នៅតំបន់អភិរក្សក្បែរខាង ដែលមិនមានព្រៃឈើដុះ ។
- សូមជួយរកទីតាំងជន្លៀសប្រជាពលរដ្ឋពេលទឹកលិចឱ្យបានសមស្រប ។
- សូមពិនិត្យលើហេតុប៉ះពាល់លើធនធានរ៉ែ ជៀសវាងប៉ះពាល់ដល់រ៉ែត្បូង ដូចនៅតាតៃលើមានរ៉ែត្បូង ។
- សូមឱ្យក្រុមហ៊ុនជួយការពារសត្វតាមអនុសញ្ញា CITES ។
- សូមឱ្យក្រុមហ៊ុនអប់រំបុគ្គលិកកម្មកររបស់ខ្លួនមិនឱ្យជួញដូរ ឬចរាចរសត្វព្រៃក្នុងតំបន់គំរោង ។
- ការប្រើប្រាស់រណាយន្តត្រូវមានលិខិត ផ្តាកសញ្ញារបស់រដ្ឋបាលព្រៃឈើ ។

### ៦.៣.៨ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយ តំណាងមន្ទីររៀបចំដែនដីនគររូបនីយកម្ម និង សំណង់ ខេត្តកោះកុង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **កែ ពុទ្ធី** អនុប្រធានមន្ទីរដែនដីនគររូបនីយកម្ម និង សំណង់ ខេត្តកោះកុង ធ្វើឡើងនៅម៉ោង ១៦ : ០០ ដល់ ១៧ : ០០ ថ្ងៃទី ០៨/១១/២០០៧ ហើយលោកតំណាងមន្ទីរនេះបានមានប្រសាសន៍ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- នៅក្នុងតំបន់អភិរក្ស មន្ទីរមិនចេញប្លង់កម្មសិទ្ធសំគាល់អចលលនះវត្ថុឱ្យទេ លើកលែងតែដីភូមិដ្ឋាន ស្រែចំការចាស់ ដែលមានអ្នកភូមិរស់នៅតាំងពីមុន ឆ្នាំ ២០០៣ ។
- នៅក្នុងតំបន់នោះមានប្រជាពលរដ្ឋរស់នៅមិនច្រើនកុះករដូចតំបន់ផ្សេងៗនៅខេត្តកោះកុងនេះទេ ហើយប្រជាពលរដ្ឋទាំងនោះមិនទាន់ធ្វើប្លង់កម្មសិទ្ធិទេ គឺគ្រាន់តែមានលិខិតស្នាមត្រឹមភូមិ ឬឃុំប៉ុណ្ណោះ ចំពោះដីសម្បទានសង្គមកិច្ចពុំបានឃើញខាងដេអំណាចមូលដ្ឋានដាក់ស្នើសុំមកមន្ទីរទេ ។
- ម្យ៉ាងទៀតមន្ទីរបានត្រឹមធ្វើការចុះបញ្ជីដីរដ្ឋបាលរបស់រដ្ឋ និង ព្រំប្រទល់ជាប់ដីរដ្ឋមួយចំនួន នៅស្រុកថ្មបាំងប៉ុណ្ណោះ ។
- លោកគាំទ្រក្នុងការអភិវឌ្ឍន៍វារីអគ្គិសនីនេះ ព្រោះអាចឱ្យប្រជាពលរដ្ឋក្នុងខេត្តកោះកុងនេះ មានថាមពលអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ និងអាចចែកចាយទៅតាមបណ្តាខេត្ត-ក្រុងផ្សេងបានទៀតផង ។

**សំណូមពរ :**

- ចំពោះការប៉ះពាល់ដល់អ្នកដែល និងត្រូវលិចលង់ សូមឱ្យមានដំណោះស្រាយជន្លៀសប្រជាពលរដ្ឋ : ទាំងនោះ ដោយស្រង់ស្ថិតិច្បាស់លាស់រួចរាយការណ៍ជូនខេត្ត និង អង្គភាពពាក់ពន្ធ័ ស៊ើចានការដោះស្រាយពីខេត្ត ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅតំបន់ដែលអាចប្រកបអាជីវកម្មបានឡើងវិញ ។
- សូមក្រុមហ៊ុនជួយអភិវឌ្ឍផ្លូវសាធារណៈឬផ្លូវរបស់គំរោង និងបើកឱ្យមានការធ្វើចរាចរជាសាធារណៈផង
- សូមឱ្យមានការកំណត់ច្បាស់លាស់នូវរចនាសម្ព័ន្ធដែលត្រូវហាមឃាត់ សំរាប់ការងារគ្រប់គ្រង និងអភិរក្សសត្វព្រៃ ។

Draft

### ៦.៣.៩ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងអង្គការអភិរក្សអន្តរជាតិ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **សេង មិនរ៉ា** នាយកអង្គការអភិរក្សអន្តរជាតិ (CI) ប្រចាំប្រទេសកម្ពុជា និងលោក **អ៊ុក គីមសាន** តំណាងរដ្ឋបាលព្រៃឈើ ទទួលបន្ទុកគ្រប់គ្រងកម្មវិធីអភិរក្សប្រចាំ CI ធ្វើឡើងនៅម៉ោង ០៩:៣០ ដល់ ១០ : ៣០ ថ្ងៃទី ១២/១១/២០០៧ ហើយលោកតំណាងអង្គការនេះបានមានប្រសាសន៍ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- ផ្អែកតាមអនុក្រិត្យលេខ ៧៧ អនក្រ.បក ស្តីពីការបង្កើតតំបន់ព្រៃការពារអភិរក្សជីជំរាលជួរភ្នំក្រវាញភាគកណ្តាល និងជីវចំរុះ អង្គការ CI បានធ្វើការងារជាមួយនឹងសហគមន៍មូលដ្ឋានអំពីការងារអភិរក្សធនធានធម្មជាតិតាមភូមិ ឃុំក្នុងតំបន់គំរោង ។ នៅក្នុងតំបន់ទាំងមូលត្រូវបានចំណាត់ថ្នាក់ទៅតាមលក្ខណៈភូមិសាស្ត្រ និងជីវៈចំរុះ ដូចជា ក្នុងនោះតំបន់ជ្រលងជាយអារ៉ែងបានចាត់ជា តំបន់លេខ ១ ខាងផ្នែកជីវសាស្ត្រចំរុះ និងលក្ខណៈភូមិសាស្ត្រ ដែលមានផ្ទៃដី ទំហំ ៣០.០០០ ហិកតា នៃតំបន់អភិរក្សទាំងមូល ៥០០.០០០ ហិកតា ។
- ចំពោះគំរោងអភិរក្សត្រីនាគ CI ចំណាយក្នុងមួយឆ្នាំ ២០.០០០ដុល្លា ការចំណាយនេះត្រូវប្រើប្រាស់តាមវិធីល្បាតវិលជុំតាមគ្រួសារ ដែលមួយលើក១មានគ្នាប្រាំនាក់រួមមាន អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ច Ranger ប្រជាពលរដ្ឋ ។ ការចំណាយក្នុងម្នាក់ ៥ ដុល្លា ក្នុងមួយយប់ សំរាប់សមាជិកសហគមន៍អ្នកល្បាតនេះ ។
- តំបន់ជួរភ្នំក្រវាញជាប្រភេទតំបន់អភិរក្សធំជាងគេនៅអាស៊ីដូចនេះ CI មានការបារម្ភខ្លាចយកតំបន់នេះធ្វើជាតំបន់អភិវឌ្ឍ នឹងធ្វើឱ្យបាត់បង់ធនធានធម្មជាតិ ។
- ថវិកាគំរោងអភិរក្សបានមកពីប្រទេសបារាំងហើយបារាំងចង់ឱ្យកម្ពុជារក្សាទុកតំបន់ភ្នំក្រវាញនេះជាតំបន់អភិរក្សធនធានធម្មជាតិរបស់ពិភពលោក ។
- នៅតំបន់គំរោងដូចជាទឹកដីឃុំថ្មដូនពៅរហូតទៅដល់ជីផាតនិងតំបន់ដល់តាតៃលើជារបៀងរបស់សត្វដំរីឆ្លងកាត់ ហើយដំរីទាំងនេះត្រូវបានអភិរក្សយ៉ាងសំខាន់ក្នុងឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។ ដូចនេះក្រុមការងារគួរតែសិក្សាថា តើវានឹងអាចប៉ះពាល់ដល់ជំរក និង របៀងសត្វដំរីដែរឬទេនៅពេលដែលគំរោងសាងសង់ និងដំណើរការ ។
- ម្យ៉ាងទៀតនៅតាមស្ទឹងជាយអារ៉ែងមានក្រពើភ្នំតែងធ្វើចរាចរចុះឡើងនៅរដូវវស្សា រីឯនៅរដូវប្រាំងវិញសត្វក្រពើភ្នំបានប្រមូលផ្តុំ ទៅរស់នៅត្រពាំងធម្មជាតិ ដូចជាបបុស្សតូច និងបបុស្សធំស្ថិតនៅខាងលើទំនប់ Site A ហើយនិងតាមតំបន់វាលខ្សាច់តាមដងស្ទឹងខាងក្រោមទីតាំងទំនប់នេះ ។
- នៅក្នុងតំបន់ជាយអារ៉ែងនេះសំបូរសត្វស្វា និងទោច ហើយសត្វទាំងនេះមានច្រើនជាងតំបន់អាតៃ ដែលស្ថិតនៅចំកណ្តាលតំបន់អភិរក្សនេះ ។ ចំពោះសត្វទោច វាចាប់ផ្តើមយំពីម៉ោង ៩ ដល់ ម៉ោង ១១ព្រឹក និងល្ងាចពីម៉ោង ៤ ដល់ ម៉ោង ៥ ពេលក្រុមការងារ SAWAC ចុះសិក្សាក៏អាចស្តាប់ឮវាផងដែរ ។
- បន្ថែមទៀតនេះ CI បានសិក្សាស្រាវជ្រាវរកឃើញសត្វស្លាបមានរហូតដល់ ៩៣ ប្រភេទ , ថនិកសត្វ ៥៧ ប្រភេទ , ល្មូន ៥៥ ប្រភេទ , និងត្រី ៤៣ ប្រភេទ ។

- លក្ខខ័ណ្ឌរបស់សហគមន៏ក្នុងការធ្វើនេសាទ គឺមិនឱ្យប្រើប្រាស់ឧបករណ៍មង ឬ សំណាញ់ទៅនៅក្នុងតំបន់ក្រពើរស់នៅ ដែលមានដាក់ផ្លាកសញ្ញាសំគាល់នៅទីនោះ ដោយខ្លាចប៉ះពាល់ដល់កូនក្រពើ ឬត្រីនាគ ។
- នៅតំបន់ត្រពាំងធម្មជាតិ ដែលស្ថិតនៅជិតភូមិចំណារ សំបូរក្ងោកដែលជាគោលដៅមួយក្នុងការអភិរក្សតំបន់នោះផងដែរ ។

**សំណូមពរៈ**

- សូមឱ្យប្តូរទីតាំងគំរោងសាងសង់វារីអគ្គិសនីជាយអារ៉ែងទៅកន្លែងផ្សេងទៀតបើអាចធ្វើទៅបាន ។
- សូមឱ្យក្រុមហ៊ុន ឬរាជរដ្ឋាភិបាលសងជាសំណងឱ្យបានសមស្រប លើការខូចខាតលើធនធានសង្គម និងមានថវិកាគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបរិស្ថាន ប្រសិនបើមានការអភិវឌ្ឍន៍នៅក្នុងតំបន់នោះ ។
- សូមឱ្យក្រុមការងារ SAWAC ពេលដែលសិក្សាចប់ រាយការណ៍ជូន CI ផង ។
- សូមឱ្យនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន អនុញ្ញាតិឱ្យតំណាងរបស់ខ្លួនចូលរួមប្រជុំជាមួយអន្តរក្រសួងក្នុងពេលធ្វើការអនុម័តលើរបាយការណ៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង នេះផង ។

### ៦.៣.១០ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយគណៈកម្មការអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **កែវ សារុន** មេឃុំថ្មដូនពៅ , លោក **ជិត ធី** ជំទប់ទី១ , និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ៣ នាក់ទៀត ព្រមទាំងប្រជាពលរដ្ឋចំនួន ៣២ នាក់ ធ្វើឡើងនៅម៉ោង ០៩:២០ ដល់ ១០ : ៣០ ថ្ងៃទី ១៥/១១/២០០៧ មានដូចតទៅ :

- អស់លោកជាគណៈកម្មការអភិវឌ្ឍន៍ឃុំ ក៏ដូចជាមេឃុំដែរ និងប្រជាពលរដ្ឋ មិនបានដឹងច្បាស់អំពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនេះទេ គឺគ្រាន់តែឃើញក្រុមហ៊ុនចិនមកសិក្សាប៉ុណ្ណោះ ។ ពួកគាត់ទើបដឹងច្បាស់អំពីគំរោងនេះនៅពេលដែលក្រុមការងារ SAWAC ពន្យល់ផ្សព្វផ្សាយ និងប្រឹក្សាជាមួយគាត់ ។
- ពួកគាត់មានការព្រួយបារម្ភ និងភ័យខ្លាចចំពោះការធ្វើហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះ ចំលើដីលំនៅដ្ឋាន ដីស្រែចំការរបស់ពួកគាត់ ។ ប្រសិនបើការអភិវឌ្ឍន៍នេះចំលើលំនៅដ្ឋាន ឬចំលើដីស្រែចំការ ពួកគាត់គ្មានអ្វីរស់នៅ និងគ្មានដីសម្រាប់បង្កបង្កើនផល ដើម្បីដោះស្រាយជីវភាពនោះទេ ពីព្រោះដីតំបន់នេះត្រូវបានអភិរក្សដោយអង្គការ CI និងរដ្ឋបាលព្រៃឈើ មិនអាចចាប់យកដីព្រៃឈើថ្មីបានទេ ។
- ពួកគាត់មិនប្រឆាំងនឹងគំរោងនេះទេ ក៍ប៉ុន្តែសូមឱ្យក្រុមហ៊ុន និងរដ្ឋាភិបាលមេត្តាដោះស្រាយដីដែលនឹងត្រូវបាត់បង់ដោយសារគំរោងនេះឱ្យបានសមស្រប ជាពិសេសសូមឱ្យបង្កើតកន្លែងថ្មីសម្រាប់ដាក់អ្នកដែលប៉ះពាល់ដោយសារគំរោងនៅតំបន់ ៧១ វាលធំ និងព្រលានយន្តហោះ ពីព្រោះដីទាំងនេះនៅទំនេរ ដែលជនាន់ប៉ុលពតជាដីកសិកម្ម តែសព្វថ្ងៃមានព្រៃឈើ ដុះឡើងវិញមួយចំនួនទៅហើយ ។
- សូមរើទីតាំងភូមិព្រែកស្វាយឱ្យទៅនៅក្នុងតំបន់នោះផងដែរ ប៉ុន្តែដីស្រែចំការដែលស្ថិតនៅក្រោមទំនប់ Site A ទុកជារបស់គាត់ដូចដើម ពោលគឺរើតែដីលំនៅដ្ឋាន និងផ្ទះសម្បែងទេ ព្រោះខ្លាចបាក់ទំនប់នៅថ្ងៃក្រោយ ។

- ពួកគាត់គាំទ្រគំរោងនេះ តែសូមឱ្យរដ្ឋាភិបាល និងក្រុមហ៊ុនផ្តល់ភ្លើងដល់កន្លែងពួកគាត់ផង ហើយភ្លើងអគ្គិសនីនេះសូមឱ្យមានតំលៃថោក សម្រាប់ការអភិវឌ្ឍន៍នៅក្នុងភូមិឃុំរបស់គាត់ ។

**៦.៣.១១ តំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយគណៈកម្មការអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋភូមិច្រកឫស្សី និងភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង**

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **គួយ ផុន** មេឃុំជំនាប់ , លោក **យ៉ុង ម៉ូ** ជំទប់ទី២ , និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ៣ នាក់ទៀត ព្រមទាំងប្រជាពលរដ្ឋចំនួន ៦៩ នាក់ ធ្វើឡើងនៅម៉ោង ០៩:០០ ដល់ ១០ : ៣០ ថ្ងៃទី ១៧/១១/២០០៧ មានដូចតទៅ :

- អស់លោកជាគណៈកម្មការអភិវឌ្ឍន៍ឃុំ ក៏ដូចជាមេឃុំដែរ និងប្រជាពលរដ្ឋ មិនបានដឹងច្បាស់អំពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនេះទេ គឺគ្រាន់តែឃើញក្រុមហ៊ុនចិនមកសិក្សាប៉ុណ្ណោះ ។ ពួកគាត់ទើបដឹងច្បាស់អំពីគំរោងនេះនៅពេលដែលក្រុមការងារ SAWAC ពន្យល់ផ្សព្វផ្សាយ និងប្រឹក្សាជាមួយគាត់ ។
- ពួកគាត់មិនចង់រុះរើផ្ទះសម្បែងទៅនៅកន្លែងផ្សេងនោះទេ ពីព្រោះពួកគាត់មករស់នៅទីនេះតាំងពីជីដូនជីតាមកម្លេះ លើកលែងតែសម័យសង្គ្រាម ដែលពួកគាត់ទៅរស់នៅជីផាត ។ តែបើរដ្ឋាភិបាលត្រូវការអភិវឌ្ឍន៍តំបន់នេះ ប៉ះពាល់ដល់ផ្ទះសម្បែង ដីស្រែចំការ ដីព្រៃអ្នកតា សូមឱ្យរដ្ឋាភិបាល និងក្រុមហ៊ុនមេត្តារកដីនៅក្បែរតំបន់នេះ ដើម្បីធ្វើការដោះដូរដីដែលត្រូវបាត់បង់ទាំងនោះវិញ ពួកគាត់នឹងគាំទ្រគំរោង ។
- ពួកគាត់ក៏បានចង្អុលបង្ហាញទីតាំងសម្រាប់ធ្វើកន្លែងតាំងទីលំនៅថ្មីឡើងវិញ នៅតំបន់វាលធំ តំបន់ ៧១ និងព្រលានយន្តហោះចាស់ ក៏ប៉ុន្តែនៅក្រៅពីតំបន់នេះពួកគាត់មិនសុខចិត្តទៅរស់នៅទេ ។ ម្យ៉ាងទៀតនៅកន្លែងតាំងទីលំនៅថ្មីនោះ សូមឱ្យក្រុមហ៊ុន និងរដ្ឋាភិបាលធ្វើផ្ទះ រៀបចំដីស្រែចំការដោយបានសំអាតជំរួច មិនមែនប្រគល់ដីព្រៃឱ្យគាត់នោះទេ ហើយកន្លែងនោះត្រូវមានហេដ្ឋារចនាសម្ព័ន្ធជនបទរួចជាស្រេច ដូចជា ផ្លូវថ្នល់ អណ្តូងទឹកស្អាត សាលារៀន សាលាឃុំ មន្ទីរពេទ្យ កន្លែងលក់ដូរជាដើម ។
- ពួកគាត់ក៏បានបញ្ជាក់ផងដែរថា ប្រសិនបើគ្មានការសាងសង់ផ្ទះសម្បែងថ្មី និងធ្វើហេដ្ឋារចនាសម្ព័ន្ធជនបទទាំងនោះរួចហើយទេ ពួកគាត់មិនចេញពីនេះដាច់ខាត ។ នៅពេលសង់កន្លែងថ្មីនោះហើយត្រូវផ្តល់មធ្យោបាយក្នុងការដឹកជញ្ជូនទ្រព្យសម្បត្តិរបស់ពួកគាត់ទៅទីនោះឱ្យបានសមស្រប ។
- ពួកគាត់ទាមទារឱ្យក្រុមហ៊ុន និងរដ្ឋាភិបាលសងនូវការប៉ះពាល់ឱ្យបានសមរម្យដល់ដំណាំដាំដុះរបស់គាត់ ដូចជាស្វាយ ដូង ខ្នុរ ចេក អំពៅ ។ល។ គឺធ្វើយ៉ាងណាសំណងដែលធ្វើឱ្យពួកគាត់រកទិញពូជ និងកូនឈើសម្រាប់ដាំក្នុងដីថ្មីទាំងនោះវិញ ។ បន្ថែមទៀតគាត់បានសំណូមពរឱ្យរដ្ឋាភិបាលគិតគូរអំពីការស្តារជីវភាពរស់នៅរបស់គាត់ឱ្យបានដូច ឬប្រសើរជាងបច្ចុប្បន្ន (ខែវិច្ឆិកា ២០០៧) ។
- នៅកន្លែងតាំងទីលំនៅថ្មីនោះ ត្រូវផ្តល់ភ្លើងអគ្គិសនីពីវារីអគ្គិសនីនេះ ហើយសូមឱ្យមានតំលៃថោកទៀតផង ។ ជួនកាលកន្លែងដែលផលិតអគ្គិសនីមិនបានភ្លើងប្រើទេ គឺបានភ្លើងប្រើនៅក្នុងតំបន់ឆ្ងាយ ដូចជាភ្នំពេញ និងទីរួមធំៗប៉ុណ្ណោះ ។

### ៦.៣.១២ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយគណៈកម្មការអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋ ភូមិប្រឡាយ, ភូមិសំរោង, ភូមិចំណារ, ភូមិតាឲិល/ធំពង្រៃ ឃុំប្រឡាយ ស្រុកថ្មបាំង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **គឹម ឆែ** មេឃុំប្រឡាយ , លោក **យង់ ដុល** ជំទប់ទី១ , និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ២ នាក់ទៀត ព្រមទាំងប្រជាពលរដ្ឋចំនួន ១៤២ នាក់ ធ្វើឡើងនៅម៉ោង ០៩:៣០ ដល់ ១១ : ១០ ថ្ងៃទី ១៩/១១/២០០៧ មានដូចតទៅ :

- អស់លោកជាគណៈកម្មការអភិវឌ្ឍន៍ឃុំ ក៏ដូចជាមេឃុំដែរ និងប្រជាពលរដ្ឋ មិនបានដឹងច្បាស់អំពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនេះទេ គឺគ្រាន់តែឃើញក្រុមហ៊ុនចិនមកសិក្សាប៉ុណ្ណោះ ។ ពួកគាត់ទើបដឹងច្បាស់អំពីគំរោងនេះនៅពេលដែលក្រុមការងារ SAWAC ពន្យល់ផ្សព្វផ្សាយ និងប្រឹក្សាជាមួយគាត់ ។
- ស្ទឹងជាយអារ៉ែងជាផ្លូវទឹក និង ជាកន្លែងនេសាទដ៏សំខាន់សំរាប់ប្រជាពលរដ្ឋ ចំពោះទិន្នផលនេសាទជាលក្ខណៈគ្រួសារគិតជាមធ្យមប្រចាំឆ្នាំនៅឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំប្រឡាយមានពី ៤០០-៦០០តោន។
- ស្ទឹងជាយអារ៉ែងបានផ្តល់ទឹកប្រើប្រាស់ ទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការស្រោចស្រពស្រែចំការ ។
- តំបន់គំរោងជាតំបន់ដែលសំបូរទៅដោយសត្វព្រៃ និងព្រៃឈើជាច្រើនប្រភេទ ព្រមទាំងពពួកសត្វកំរដែលកំពុងមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការ CI និង WildAid ។

**បញ្ហាចំបងដែលបានលើកឡើង :**

- ប្រជាពលរដ្ឋមានការព្រួយបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួន នៅពេលមានការស្រុតបាក់ទំនប់វារីអគ្គិសនី និងមានការលិចលង់នេះ ។
- មានការបាត់បង់ផ្ទះសម្បែង ដីធ្លី ស្រែចំការ ផលដំណាំ សត្វពាហនៈដូចជា ក្របី ជ្រូក មាន់ទា របស់ប្រជាពលរដ្ឋបាត់មុខរបរចិញ្ចឹមជីវិត កូនគ្មានសាលារៀន គ្មានវត្តអារ៉ាម និងកន្លែងសក្ការៈបូជានានា ។

**សំណូមពររបស់ប្រជាពលរដ្ឋ :**

- ពួកគាត់មិនជំទាស់នឹងគំរោងនេះទេ តែសូមឱ្យមានសំណងនូវការខូចខាតផ្ទះសម្បែង និងផលដំណាំ ព្រមទាំងមានការដោះដូរដីធ្លី ស្រែចំការឱ្យបានសមស្រប ។
- សូមឱ្យមានការផ្តល់ដីសម្បទានសង្គមកិច្ចបំរុងសំរាប់បង្ការពេលបាក់ទំនប់ នៅពេលសាងសង់ និងពេលដំណើរការគំរោង ។
- សូមយកដីសម្បទានសង្គមកិច្ច ដែលមានទីតាំងវាលធំ ( វាលយន្តហោះចាស់ ) និងស្ទឹងតូច
- ដីបំរុងនោះ ត្រូវមានសាងសង់ផ្លូវស្ពាន សាលារៀន មណ្ឌលសុខភាព វត្តអារ៉ាម ទឹកស្អាត អគ្គិសនី និងសន្តិសុខ សណ្តាប់ធ្នាប់ល្អ ។



Draft

### ៦.៣.១៣ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយអភិបាលរងស្រុកថ្មបាំង

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **សៀវ សាធន** អភិបាលរងស្រុកថ្មបាំង ខេត្តកោះកុង ធ្វើឡើង នៅម៉ោង ១៤ : ០០ ដល់ ១៥ : ០០ ថ្ងៃទី ២១/១១/២០០៧ ហើយលោកអភិបាលរងបានមានប្រសាសន៍ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- បច្ចុប្បន្នការរស់នៅក្រោមការអភិរក្សធនធានធម្មជាតិក្នុងតំបន់ជាយអារ៉ែងនេះ គឺយើងតែងតែជួបប្រទះនូវបញ្ហាខ្វែងគំនិតគ្នាជាមួយក្រុមអភិវឌ្ឍន៍ និងក្រុមអភិរក្សតែបញ្ហាធំយើងត្រូវថ្លឹងថ្លែងថាមួយណាមានការរីកចំរើនដល់ប្រទេសជាតិ និងប្រជាជនមានជីវភាពធូរធារសំបូររុងរឿងនៅពេលអនាគត ។
- ចំពោះអាជ្ញាធរស្រុកមានការគាំទ្រទាំងស្រុងលើការអភិវឌ្ឍន៍វារីអគ្គិសនីនេះរបស់រាជរដ្ឋាភិបាល ពីព្រោះវានឹងផ្តល់ផលប្រយោជន៍យ៉ាងធំធេងសម្រាប់វិស័យអគ្គិសនីដែលជាថាមពលសំខាន់សម្រាប់អភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ។
- ចំពោះការស្នើសុំទីតាំងសំរាប់លំនៅដ្ឋានថ្មីនៅវាលធំ វាល៧៣ និងវាលយន្តហោះចាស់ដោយប្រជាពលរដ្ឋនេះ គឺមានលក្ខណៈភូមិសាស្ត្រសមស្រប ពីព្រោះទីនោះជាដីសាធារណៈរបស់រដ្ឋ មិនទាន់នរណាកាន់កាប់នៅឡើយ ម្យ៉ាងទៀតដីនេះមានទំហំសមល្មមជាមួយនឹងចំនួនប្រជាជន ដែលរស់នៅក្នុងឃុំជំនាប់ និងប្រឡាយនៃគំរោងនេះ ។
- គុណភាពដីនៅវាលធំ វាល៧៣ និងវាលយន្តហោះចាស់នេះ មានជីវជាតិល្អ (ដីក្រហម) ដូចដីនៅទីរួមស្រុកថ្មបាំង ហើយបើប្រៀបធៀបទៅនឹងគុណភាពដីនៅកន្លែងតាំងលំនៅដ្ឋានថ្មីនេះ ទៅនឹងឃុំប្រឡាយ និងឃុំថ្មដូនពៅ គឺល្អជាង ។ក៏ប៉ុន្តែនៅកន្លែងនោះ គឺមានដីទំនាបសំរាប់ធ្វើស្រែតិចតួច តែអាចធ្វើស្រែទួល និងបានទិន្នផលខ្ពស់ទៀតផង រួមទាំងអាចដាំដំណាំរួមផ្សំបានយ៉ាងល្អប្រសើរ ព្រោះកាលជំនាន់ប៉ុលពតដីកសិកម្មទាំងនេះបានឱ្យផលកសិកម្មខ្ពស់ ។
- លោកគាំទ្រគំរោងនេះទាំងស្រុង ហើយលោកបានបញ្ជាក់ថែមទៀតថា ការអភិវឌ្ឍន៍តំបន់នេះមានផ្លូវគមនាគមន៍ចេញចូលល្អ មានអាងទឹកធំធ្វើ ឱ្យទេសចរណ៍ជាតិ និងអន្តរជាតិមានការកើនឡើង ដែលជាប្រភពចំណូលដ៏ប្រសើរដល់ប្រជាជនក្នុងមូលដ្ឋានផ្ទាល់ក៏ដូចជាចំណូលចូលប្រទេសជាតិតាមរយៈ ទេសចរណ៍អន្តរជាតិ ពីព្រោះតំបន់នេះមានសក្តានុពល ទេសចរណ៍ធម្មជាតិយ៉ាងល្អប្រសើរ ដូចជា ខ្នងភ្នំស្រល់ដែលភ្ជាប់ខេត្តកោះកុងទៅខេត្តកំពង់ស្ពឺជាដើម ។

**សំណូមពរ :**

- សូមឱ្យក្រុមហ៊ុននិងរដ្ឋាភិបាលផ្តល់ភ្លើងអគ្គិសនី និងមានតំលៃថោកជូនប្រជាពលរដ្ឋក្នុងស្រុកថ្មបាំងរបស់យើងខ្ញុំផង
- សូមឱ្យមានការសាងសង់ស្ពាន ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព ទឹកស្អាត និងផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងតំបន់ ។
- សូមឱ្យរាជរដ្ឋាភិបាលជួយរកទីផ្សារកសិកម្មសំរាប់ប្រជាពលរដ្ឋនៅស្រុកថ្មបាំងនេះផង ។

Draft

- សូមឱ្យក្រុមការងារសិក្សាហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ ជួយសិក្សាស្ថានភាពភូមិសាស្ត្រដីសំរាប់ធ្វើកសិកម្ម ជូនប្រជាពលរដ្ឋ ដែលនឹងផ្លាស់ប្តូរទីលំនៅទៅកាន់ទីនោះផង ។

### ៦.៣.១៤ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងអង្គការសង្គ្រោះសត្វព្រៃ WildAid និងអង្គការ Fauna & Flora International

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោកស្រី **Michell Owen** និងលោក **Hort Sokun** តំណាងអង្គការ WildAid, លោក **Boyd Simpson** តំណាងអង្គការ Fauna & Flora International ធ្វើឡើងនៅម៉ោង ១០ : ០០ ដល់ ១១ : ០០ ថ្ងៃទី ២៧/១១/២០០៧ ហើយលោក លោកស្រីតំណាងអង្គការនេះបានមានប្រសាសន៍ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- អង្គការសង្គ្រោះសត្វព្រៃចង់ឱ្យមានការបញ្ឈប់គំរោងសាងសង់វារីអគ្គិសនីនៅជាយអារ៉ែងនេះ ដោយហេតុថាតំបន់នេះសំបូរទៅដោយសត្វព្រៃ និងសត្វស្លាបជាច្រើនប្រភេទ ជាពិសេសសត្វក្រពើភ្នំ ដ៏រីដែលមាននៅតំបន់ជាយអារ៉ែង និងអូសោម ពីព្រោះពូជក្រពើនេះមាននៅសល់ច្រើននៅតំបន់នេះ នៅលើពិភពលោកបាត់បង់ស្ទើរផុតពូជអស់ហើយ ។
- ការអភិវឌ្ឍន៍វារីអគ្គិសនីនេះ នឹងអាចកើតមានការសាងសង់ផ្លូវ និងមានជនចំណាកស្រុកមករស់កាន់តែច្រើនឡើង ដែលជាហេតុបង្កឱ្យមានការកាប់ឈើ និងវាតយកដីលក់ជាពុំខានឡើយ ។
- បើគំរោងវារីអគ្គិសនីដំណើរការ តើត្រូវជម្លៀសសត្វក្រពើភ្នំទៅដោយរបៀបណា ? តើគេត្រូវការថវិកាប៉ុន្មានដើម្បីរៀបចំជំរករបស់វាឡើងវិញ ។
- តំបន់នេះជាកន្លែងសំរាប់ធ្វើការសិក្សារបស់និស្សិត អំពីសត្វក្រពើ និងសត្វព្រៃផ្សេងទៀត ។
- អង្គការ WildAid និង CI មានគំរោងបង្កើតតំបន់ភ្នំក្រវាញភាគកណ្តាលនេះ ឱ្យទៅជាតំបន់អេកូទេសចរណ៍ធម្មជាតិនៅពេលខាងមុខស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ផងដែរ ។
- ការលិចលង់ដោយសារការទប់ទំនប់វារីអគ្គិសនីនេះ នឹងធ្វើឱ្យមានផលប៉ះពាល់ដល់សំបុកពង និងកូនតូចៗរបស់សត្វក្រពើ ដែលអាចឈានទៅរកការបាត់បង់ពូជក្រពើភ្នំនេះនៅពេលអនាគត ។

### ៦.៣.១៥ កំណត់ហេតុនៃការប្រជុំពិភាក្សារវាងក្រុមការងារជាមួយតំណាងនាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ

ការប្រជុំពិភាក្សា និងប្រឹក្សាយោបល់ជាមួយ លោក **ម៉ៅ ហាក់** ប្រធាននាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ ធ្វើឡើងនៅម៉ោង ១៥ : ០០ ដល់ ១៥ : ៣០ ថ្ងៃទី ០៣/១២/២០០៧ ហើយលោកបានមានប្រសាសន៍ប្រាប់ក្រុមការងារ SAWAC ដូចតទៅ :

- កន្លងមកគ្មានទិន្នន័យណាដែលពាក់ព័ន្ធនឹងការងារជលសាស្ត្រ ដូចជា ធារទឹក កំពស់ទឹក ល្បឿនទឹក បានសិក្សានៅស្ទឹងជាយអារ៉ែង ឬប្រព័ន្ធផ្ទៃអាងរងទឹកភ្លៀងរបស់វាទេ ។
- គេអាចធ្វើការប៉ាន់ប្រមាណនូវធារទឹកអតិបរមាឬអប្បបរមាបាន ដោយធ្វើ Modelling តាមការគណនាដោយកុំព្យូទ័ររួចគេធ្វើជាគំរូដើម្បីពិសោធន៍សាកល្បង ហើយយកលទ្ធផលនេះទៅប្រៀបធៀបនៅទីកន្លែងផ្ទាល់ ។
- យោងតាមច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជា មុនពេលសាងសង់ក្រុមហ៊ុនត្រូវតែធ្វើការសុំអាជ្ញាប័ណ្ណទឹកពីក្រសួងធនធានទឹក និង ឧតុនិយមជាមុនសិន ។

Draft

## ៦.៣.១៦ កំណត់ហេតុនៃការប្រជុំបូកសរុបការងាររវាងក្រុមការងារជាមួយតំណាងអង្គការ CI, តំណាងអង្គការ FFI និងតំណាងរដ្ឋបាលព្រៃឈើប្រចាំអង្គការ CI

ក្រោយពីក្រុមការងារ SAWAC បានសិក្សាបរិស្ថានធម្មជាតិ ( ធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រ) និងបរិស្ថានសង្គមក្នុងតំបន់ដែលនឹងត្រូវប៉ះពាល់ដោយគំរោងវារីអគ្គិសនីជាយអារ៉ែងខេត្តកោះកុង អស់រយៈពេលជាងពីរខែ និងយោងតាមសំណូមពររបស់អង្គការទាំងនេះ ក្រុមការងារបានធ្វើការបូកសរុប និងប្រជុំពិភាក្សា ដែលធ្វើឡើងនៅការិយាល័យរបស់អង្គការ CI វេលាម៉ោង ០៩ : ៣០ ដល់ ១១ : ៣០ ថ្ងៃទី ១៥/០១/២០០៨ មានដូចតទៅ :

**ការប្រៀបធៀបប្រភេទសត្វព្រៃដែលរកឃើញដោយក្រុមការងារ SAWAC និងអង្គការ CI**

| ល.រ | អំបូរសត្វព្រៃ | ប្រភេទសត្វព្រៃដែលរកឃើញដោយ CI | ប្រភេទសត្វព្រៃដែលរកឃើញដោយ SAWAC | សំគាល់ |
|---|---|---|---|---|
| ១ | ថនិកសត្វ | ៥៧ | ៥៣ | ប្រភេទសត្វព្រៃដែល CI រកឃើញលើផ្ទៃដី ប្រមាណជាង២០.០០០ហ.ត។ ចំពោះប្រភេទសត្វព្រៃដែលក្រុមការងារ SAWAC រកឃើញនៅតំបន់គំរោងខាងក្នុងអាងនិងខាងក្រោមអាងលើផ្ទៃដីប្រមាណ១២.៨៨៣ ហ.ត. ប៉ុណ្ណោះ ។ |
| ២ | បក្សី | ៩៣ | ១១៣ | |
| ៣ | ឧរង្គសត្វ | ៥៥ | ៣១ | |
| ៤ | មច្ឆជាតិ | ៤៣ | ៤៣ | |
| សរុប | | **២៤៨** | **២៤០** | |

- ក្រុមការងារ SAWAC ក៏បានរាយការណ៍អំពីចំនួនប្រភេទព្រៃឈើ និងពូជឈើដែលបានពិពិណនានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ក្នុងជំពូក ៤ ចំណុច ៤.២.៥ នៅក្នុងអង្គប្រជុំផងដែរ ។
- តំណាងអង្គការទាំងពីរ ក៏មានចំណាប់អារម្មណ៍ទៅលើការអភិវឌ្ឍន៍វារីអគ្គិសនីនេះ ពោលគឺមិនជំទាស់នឹងគំរោងនេះទេ ក៏ប៉ុន្តែសូមឱ្យម្ចាស់គំរោងគិតគូរដល់កិច្ចការពារគ្រប់គ្រងបរិស្ថានក្នុងតំបន់ឱ្យបានម៉ឺងម៉ាត់បំផុត ពីព្រោះក្រោយពីការអភិវឌ្ឍន៍គំរោងនេះនឹងមានជនចំណូលថ្មីឬជនឆ្លៀតឱកាសមួយចំនួនទៀតទៅទន្រ្ទានដីតំបន់អភិរក្សដើម្បីកាន់កាប់ ។ ម្យ៉ាងទៀតសូមឱ្យម្ចាស់គំរោងគ្រោងថវិការគ្រប់គ្រាន់សំរាប់ការការពារគ្រប់គ្រងបរិស្ថាននៅក្នុងតំបន់ដីម្បីឱ្យមានប្រសិទ្ធិភាពខ្ពស់ហើយអង្គការទាំងនេះក៏បានលើកតំលៃការពារអភិរក្សក្នុងតំបន់នៅពេលដែលគំរោងចាប់ផ្តើមការសាងសង់ ដូចមានចែងក្នុងតារាងខាងក្រោម :

**តារាងនៃខ្ទង់ចំណាយសំរាប់សកម្មភាពការពារការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងតំបន់សាងសង់វារីអគ្គិសនី**

(Table of expenditure for mitigated action against illegal activities of forest in the area of Hydropower construction)

| No. | Description | Quantity | Month | Year | Prices $ | Total $ |
|---|---|---|---|---|---|---|
| I | **During hydropower construction** | | | | | |
| 1 | Increase protection | | | | | |
| | FA ranger (person) | 10 | 12 | 5 | 400 | 240,000 |
| | Military police (person) | 30 | 12 | 5 | 400 | 720,000 |
| 2 | Demarcation (2400 ha) | | | | | 25,000 |
| 3 | Set up protection outpost | 4 | | | 2,000 | 8,000 |
| 4 | Education and awareness | 4 | | 30 | 10,000 | 1,200,000 |
| 5 | Migration control management | 4 | | | 10,000 | 40,000 |
| 6 | Conflict resolution affiliation | | | 10 | 2,500 | 25,000 |
| | (FA, CI, local authority and all stakeholders | | | | | |
| II | **After hydropower construction** | | | | | |
| | Activity for year 5 to year 30 | | | | | |
| 1 | FA ranger | 6 | 12 | 30 | 400 | 864,000 |
| 2 | Military police | 14 | 12 | 30 | 400 | 2,016,000 |
| 3 | Compensation for ranger station | | | | | 30,000 |
| | Total | | | | | 5,168,000 |

Draft

## ៦.៤ ដំណោះស្រាយពីការប្រឹក្សាពិគ្រោះយោបល់ និងសំណូមពរពីសាធារណៈជន

បន្ទាប់ពីការធ្វើការប្រឹក្សាពិគ្រោះយោបល់ជាមួយសាធារណៈជន និងអ្នកដែលពាក់ព័ន្ធក្នុងគំរោងរួចមក ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង សង្គម បានធ្វើការសម្របសម្រួល និងរកដំណោះស្រាយជាមួយក្រុមហ៊ុន ដែលផ្អែកលើកំណត់ហេតុខាងលើនេះ មានដូចតទៅ:

១- ក្រុមហ៊ុននឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់ផ្លូវដែលខ្លួនបានសាងសង់ លើកលែងតែផ្លូវដែលត្រូវហាមឃាត់សម្រាប់ការពារសុវត្ថិភាពទំនប់វារីអគ្គិសនី ។

២- ក្រុមហ៊ុននឹងធ្វើផែនការតាំងទីលំនៅឡើងវិញឱ្យបានសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងផែនការនេះ មានបំភ្លឺអំពីសំណងសងដល់ការប៉ះពាល់នូវផ្ទះសម្បែង ផលដំណាំ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទ ។

៣- ក្រុមហ៊ុននឹងសិក្សាលំអិត នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីឱ្យរឹងមាំមិនឱ្យបាក់ ។

៤- ក្រុមហ៊ុននឹងសិក្សាតំបន់ភ្នំដែលនៅជុំវិញអាង ហើយរកវិធីសាស្ត្រសាងសង់ការពារភ្នំទាំងនោះមិនឱ្យរំកិលបាក់ទៅថ្ងៃអនាគត ។

៥- ក្រុមហ៊ុននឹងបើកទឹកមកខាងក្រោមទំនប់ Site A ដែលមានធារទឹកអប្បបរមាចំនួន ១,៥ម៣/វិនាទី ដោយបង្ហូរឥតដាច់ទាំងរដូវប្រាំង និងវស្សា ។

៦- កុមហ៊ុននឹងថែទាំ និងជួសជុលផ្លូវ ធ្វើស្ពានមួយកន្លែង និងលូ ៣កន្លែង ចាប់ពីទីរួមស្រុកថ្មបាំងមកដល់ទីតាំងគំរោងឱ្យល្អក្នុងពេលសាងសង់គំរោង (ការសាងសង់ផ្លូវគមនាគមន៍មើលជំពូក ៣ ចំណុច ៣.៤.៣) ។

៧- ក្រុមហ៊ុននឹងបញ្ចូលកញ្ចប់ថវិការដែលរៀបរៀងដោយអង្គការ CI សំរាប់ការគ្រប់គ្រង និងការការពារបរិស្ថានដែលមាន ចំនួនទឹកប្រាក់សរុប US$ ៥.៤៨០.០០០,០០ (ប្រាំលានបួនសែនប្រាំបីម៉ឺនដុល្លាអាមេរិចគត់) សំរាប់រយៈពេល ៤០ ឆ្នាំ។

៨- ក្រុមហ៊ុននឹងផ្តល់អាទិភាពដល់ប្រជាជននៅក្នុងភូមិជុំវិញតំបន់គំរោង ក្នុងការជ្រើសរើសបុគ្គលិកកម្មករចូលបំរើការងាររបស់គំរោងនេះ ដោយធ្វើការពិភាក្សាជាមួយអ្នកតំណាងរបស់សហគមន៍ និងជាមួយប្រជាជនផ្ទាល់ ។

៩- ក្រុមហ៊ុនមានកម្មវិធីតាមដានត្រួតពិនិត្យលើការអនុវត្តន៍គំរោងច្បាស់លាស់ ដោយមានមន្ត្រីក្រុមចំរុះជាអ្នកអង្កេតតាមដាន ដូចមានចែងនៅក្នុងជំពូកទី ៧: ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងតំបន់គំរោងនេះស្រាប់ ។

១០- ក្រុមហ៊ុន និងរាជរដ្ឋាភិបាលនឹងផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ប្រជាពលរដ្ឋ ដែលត្រូវតាំងទីលំនៅថ្មី ។

Draft

# រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង
## ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧



ប្រឹក្សាជាមួយលោក **លីញ ជៀនហ្វេង** (Ling Jianfeng)
អ្នកគ្រប់គ្រងគំរោងរបស់ក្រុមហ៊ុន CSG
ថ្ងៃទី ០៦/១១/២០០៧



ប្រឹក្សាជាមួយលោក **ម៉ុច ស៊ីយ៉ុន** ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកោះកុង
ថ្ងៃទី ០៦/១១/២០០៧



ប្រឹក្សាជាមួយលោក **អ៊ុន ឆាលី** នាយខុទ្ទកាល័យសាលាខេត្តកោះកុង
ថ្ងៃទី ០៧/១១/២០០៧



ប្រឹក្សាជាមួយលោក **ឌៃ ពេជ្ររតនា** ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង
ថ្ងៃទី ០៧/១១/២០០៧



ប្រឹក្សាជាមួយលោក **សាញ់ មុនីរត្ន** ប្រធានមន្ទីរធនធានទឹក និងឧតុនិយម
ខេត្តកោះកុង . ថ្ងៃទី ០៧/១១/២០០៧



ប្រឹក្សាជាមួយលោក **ផុន លីទិះ** ប្រធានមន្ទីរកសិកម្ម ខេត្តកោះកុង
ខេត្តកោះកុង . ថ្ងៃទី ០៨/១១/២០០៧

# រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧



ប្រឹក្សាជាមួយលោក **មាស ស៊ីថា** នាយរងខ័ណ្ឌរដ្ឋបាលព្រៃឈើ ខេត្តកោះកុង . ថ្ងៃទី ០៨/១១/២០០៧



ប្រឹក្សាជាមួយលោក **កែ ពុទ្ធី** អនុប្រធានមន្ទីរដែនដីនគររូបនីយកម្ម និង សំណង់ ខេត្តកោះកុង . ថ្ងៃទី ០៨/១១/២០០៧



ប្រឹក្សាជាមួយលោក **សេង ម៉ិនរ៉ា** នាយកអង្គការអភិរក្សអន្តរជាតិ (CI) ថ្ងៃទី ១២/១១/២០០៧



ប្រឹក្សាជាមួយលោក **កែវ សារុន** មេឃុំ និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ ឃុំថ្មដូនពៅ ស្រុកថ្មបាំង . ថ្ងៃទី ១៥/១១/២០០៧



ប្រឹក្សាជាមួយលោក **កែវ សារុន** មេឃុំ និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ និងប្រជាពលរដ្ឋ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ . ថ្ងៃទី ១៥/១១/២០០៧



សកម្មភាពក្រុមការងារ SAWAC ធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋប៉ះពាល់ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ . ថ្ងៃទី ១៥/១១/២០០៧

Draft

## <u>រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង</u>
## <u>ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧</u>



ប្រឹក្សាជាមួយលោក **ឃួន សារ៉េត** មេភូមិត្រៀក ឧបសម្ព័ន្ធភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង , ថ្ងៃទី ១៦/១១/២០០៧



ប្រឹក្សាជាមួយមេភូមិ និងប្រជាពលរដ្ឋភូមិត្រៀកឧបសម្ព័ន្ធភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង , ថ្ងៃទី ១៦/១១/២០០៧



ប្រឹក្សាជាមួយលោក **គួយ ផុន** មេឃុំ និង សមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ ឃុំជំនាប់ ស្រុកថ្មបាំង , ថ្ងៃទី ១៧/១១/២០០៧



ប្រឹក្សាជាមួយលោក **គួយ ផុន** មេឃុំ , សមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ និងប្រជាពលរដ្ឋ ឃុំជំនាប់ ស្រុកថ្មបាំង , ថ្ងៃទី ១៧/១១/២០០៧



ប្រឹក្សាជាមួយលោក **គីម ឆែ** មេឃុំ និង សមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ ឃុំប្រឡាយ ស្រុកថ្មបាំង , ថ្ងៃទី ១៩/១១/២០០៧



ប្រឹក្សាជាមួយលោក **គីម ឆែ** មេឃុំ និងសមាជិកក្រុមប្រឹក្សាអភិវឌ្ឍន៍ និងប្រជាពលរដ្ឋ ឃុំប្រឡាយ ស្រុកថ្មបាំង , ថ្ងៃទី ១៩/១១/២០០៧

Draft

# រូបថតប្រឹក្សាជាមួយស្ថាប័នពាក់ព័ន្ធ និង សាធារណជនដែលរស់នៅក្នុងតំបន់គំរោង ថ្ងៃទី ០៥/១១ ដល់ ៣១/១២/២០០៧



ប្រឹក្សាជាមួយលោក **សៀវ សាធាន** អភិបាលរងស្រុកថ្មបាំង នៅគេហដ្ឋានរបស់លោកផ្ទាល់ , ថ្ងៃទី ២១/១១/២០០៧



ប្រឹក្សាជាមួយលោកស្រី **Michell Owen**, តំណាងអង្គការ **WildAid**, និង លោក **Boyd Simpson** តំណាងអង្គការ FFI , ថ្ងៃទី ២៧/១១/២០០៧



ប្រឹក្សាជាមួយលោក **ម៉ៅ ឆាក់** ប្រធាននាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេនៃក្រសួងធនធានទឹក និងឧតុនិយម. ថ្ងៃទី ០៣/១២/២០០៧



ការបូកសរុបការងារ របស់ក្រុមការងារ SAWAC អំពីលទ្ធផលនៃការសិក្សាបរិស្ថានធម្មជាតិ និងសង្គមក្នុងតំបន់ជាយអារ៉ែង នៅការិយាល័យ អង្គការ CI ។ អ្នកចូល រួមមានតំណាងអង្គការ CI, តំណាង អង្គការ FFI និងតំណាងរដ្ឋបាលព្រៃ ឈើប្រចាំអង្គការ CI , ថ្ងៃទី ១៥/០១/២០០៨

Draft